ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ១១៩៩ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី
## តួនាទី ភារកិច្ច និងសិទ្ធិអំណាចរបស់រដ្ឋមន្ត្រីស្តីទី

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- យោងតាមសំណើរបស់រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

## សម្រេច

**មាត្រា១ .-**

អនុក្រឹត្យនេះកំណត់អំពីតួនាទី ភារកិច្ច និងសិទ្ធិអំណាចរបស់រដ្ឋមន្ត្រីស្តីទី។

**មាត្រា២ .-**

ក្នុងករណីរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រីឬរដ្ឋមន្ត្រីក្រសួងអវត្តមានឬមានភារកិច្ចមិនអាចដឹកនាំ គ្រប់គ្រងទីស្តីការគណៈរដ្ឋមន្ត្រីឬក្រសួងបាន រដ្ឋលេខាធិការប្រចាំការនៃទីស្តីការគណៈរដ្ឋមន្ត្រីឬរដ្ឋលេខាធិការនៃក្រសួងសាមីត្រូវទទួលឋានៈជារដ្ឋមន្ត្រីស្តីទី។

ក្នុងករណីដែលរដ្ឋលេខាធិការប្រចាំការមិនអាចបំពេញតួនាទីជារដ្ឋមន្ត្រីស្តីទីបាន រដ្ឋមន្ត្រីអាចចាត់តាំងរដ្ឋលេខាធិការផ្សេងទៀតជារដ្ឋមន្ត្រីស្តីទីតាមការប្រគល់សិទ្ធិ។

ក្នុងករណីរដ្ឋមន្ត្រីសាមីអវត្តមានឬមានភារកិច្ចមិនអាចដឹកនាំបាន ហើយរដ្ឋលេខាធិការប្រចាំការក៏មិនអាចបំពេញតួនាទីជារដ្ឋមន្ត្រីស្តីទីបាន នាយករដ្ឋមន្ត្រីចាត់តាំងសមាជិករាជរដ្ឋាភិបាលឬរដ្ឋលេខាធិការណាម្នាក់ជារដ្ឋមន្ត្រីស្តីទី។

**មាត្រា៣ .-**

រដ្ឋលេខាធិការប្រចាំការដែលទទួលឋានៈជារដ្ឋមន្ត្រីស្តីទីមិនមែនជាសមាជិករាជរដ្ឋាភិបាលទេ។

ក្នុងករណីដែលមានកិច្ចការចាំបាច់តាមរដ្ឋធម្មនុញ្ញ និងច្បាប់តម្រូវឱ្យរដ្ឋមន្ត្រីជាអ្នកបំពេញតួនាទីនោះ នាយករដ្ឋមន្ត្រី ចាត់តាំងសមាជិករាជរដ្ឋាភិបាលណាម្នាក់ដើម្បីបំពេញកិច្ចការងារនោះជំនួសរដ្ឋមន្ត្រីដែលអវត្តមានឬមានភារកិច្ចមិនអាចដឹកនាំ គ្រប់គ្រងបាន។ ក្នុងករណីនេះ រដ្ឋលេខាធិការប្រចាំការត្រូវធ្វើជាសេនាធិការជូនសមាជិករាជរដ្ឋាភិបាលដែលត្រូវបានចាត់តាំងឱ្យមកបំពេញភារកិច្ចនោះ។ ក្នុងករណីចាំបាច់ សមាជិករាជរដ្ឋាភិបាលនោះត្រូវស្នើសុំយោបល់ដឹកនាំដោយផ្ទាល់ពីនាយករដ្ឋមន្ត្រី។

**មាត្រា៤ .-**

រដ្ឋមន្ត្រីស្តីទីមានតួនាទី ភារកិច្ច និងសិទ្ធិអំណាចក្នុងការដឹកនាំ គ្រប់គ្រងការងារទីស្តីការគណៈរដ្ឋមន្ត្រីឬក្រសួងសាមីក្នុងនាមរដ្ឋមន្ត្រី លើកលែងតែការតែងតាំង ផ្លាស់ប្តូរ និងបញ្ចប់មុខតំណែងមន្ត្រីរាជការ ការដំឡើងឋានន្តរសក្តិឬថ្នាក់មន្ត្រីរាជការ ព្រមទាំងការចាត់ចែងចំណូលចំណាយថវិកាផ្ទុយពីគោលការណ៍ដែលបានកំណត់រួចហើយ និងក្រៅពីគម្រោងថវិកាដែលបានអនុម័ត។

ក្នុងករណីចាំបាច់ រដ្ឋមន្ត្រីស្តីទីអាចរាយការណ៍និងសុំយោបល់ដឹកនាំពីនាយករដ្ឋមន្ត្រី។

**មាត្រា៥ .-**

នាយករដ្ឋមន្ត្រីអាចដឹកនាំ គ្រប់គ្រងដោយផ្ទាល់ទីស្តីការគណៈរដ្ឋមន្ត្រីនិងក្រសួងមួយចំនួនទៀតតាមការចាំបាច់ ក្នុងករណីរដ្ឋមន្ត្រីសាមីអវត្តមានឬមានភារកិច្ចមិនអាចដឹកនាំគ្រប់គ្រងបាន។

**មាត្រា៦ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះត្រូវទុកជានិរាករណ៍។

**មាត្រា៧ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃព្រហស្បតិ៍ ១១រោច ខែស្រាពណ៍ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៦ ខែកញ្ញា ឆ្នាំ២០១៨

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី សូមហត្ថលេខា

**ឧបនាយករដ្ឋមន្ត្រីប្រចាំការ**

**រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

កិត្តិនីតិកោសលបណ្ឌិត **ប៊ិន ឈិន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៧
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ